# គំនិតផ្តួចផ្តើមសុខមាលភាពសហគមន៍ (The Community Well-Being Initiative)៖ ការគាំទ្រកម្មវិធីធានាប្រាក់ចំណូល

ទីភ្នាក់ងារសេវាកម្មសង្គមកិច្ចនៃខោនធី Alameda (Alameda County Social Service Agency) មានសេចក្តីរីករាយសូមប្រកាសអំពីគំនិតផ្តួចផ្តើមសុខមាលភាពសហគមន៍ (Community Well-Being Initiative) ដែលទទួលបានថវិកា តាមរយៈការឧបត្ថម្ភគាំទ្រដ៏សប្បុរសធម៌ពីមូលនិធិ Hellman Foundation។ គំនិតផ្តួចផ្តើមនេះ មានគោលបំណងដើម្បីពង្រីកកម្មវិធីធានាប្រាក់ចំណូល (Guaranteed Income) ដែលបានបង្កើតនាបច្ចុប្បន្ន ដែលបម្រើសេវាកម្មជូនអ្នករស់នៅក្នុងខោនធី Alameda។

**ថ្ងៃកំណត់ត្រូវដាក់ពាក្យសុំ៖** ថ្ងៃកំណត់ត្រូវដាក់ពាក្យសុំ គឺ**ថ្ងៃទី 10 ខែ តុលា ឆ្នាំ 2025 ម៉ោង 5pm**។ រាល់ពាក្យសុំទាំងអស់ត្រូវតែទទួលបានតាមប្រព័ន្ធអេឡិចត្រូនិកដោយទីភ្នាក់ងារសេវាកម្មសង្គមកិច្ចនៃខោនធី Alameda (ACSSA)។ **ពាក្យសុំយឺតយ៉ាវ នឹងមិនត្រូវទទួលយកឡើយ។**

ពាក្យសុំ ដែលជោគជ័យ នឹងត្រូវប្រកាសនៅចុងខែតុលា ឆ្នាំ 2025។

**រាល់សេចក្តីសម្រេចទាំងអស់អំពីការផ្តល់មូលនិធិ គឺជាសេចក្តីសម្រេចស្ថាពរ។ ពុំមាននីតិវិធីប្តឹងតវ៉ាលើសេចក្តីសម្រេចអំពីពាក្យសុំឡើយ។**

**ដើម្បីដាក់ពាក្យសុំ សូមបំពេញ និងដាក់ពាក្យសុំរបស់អ្នកតាមអ៊ីម៉ែលមក៖**
**SSAInnovations@acgov.org**

រាល់ឯកសារពាក្យសុំទាំងអស់ត្រូវតែដាក់មកតាមអ៊ីម៉ែលតែមួយគត់។ ឯកសារជាសន្លឹកក្រដាសនឹងមិនត្រូវទទួលយកឡើយ។

## ប្រវត្តិសាវតា

ខោនធី Alameda មានពលរដ្ឋជាង 1.6 លាននាក់ ដែលរស់នៅក្នុងទីក្រុងស្វ័យតចំនួន 14 និងសហគមន៍អស្វ័យតជាច្រើន ជាហេតុធ្វើឲ្យខោនធីក្លាយជាខោនធីមានប្រជាជនច្រើនបំផុតទី 7 នៅក្នុងរដ្ឋ និងទី 21 នៅក្នុងសហរដ្ឋអាមេរិក។ ខោនធី Alameda ត្រូវបានគេស្គាល់ថាជាខោនធីចម្រុះវប្បធម៌ និងមានប្រវត្តិបត់បែនសម្បូរបែប ប៉ុន្តែពលរដ្ឋ 9.5% របស់ខោនធី គឺរស់នៅក្នុងភាពក្រីក្រ។ បើទោះបីជាអត្រាភាពក្រីក្ររបស់ខោនធី Alameda ទាបជាងអត្រាមធ្យមរបស់រដ្ឋ California និងសហរដ្ឋអាមេរិកក៏ដោយ ក៏ប៉ុន្តែបុគ្គល និងគ្រួសារនៅតែជួបការលំបាកក្នុងការចិញ្ចឹមជីវិត។ កត្តាជាច្រើនបានរួមចំណែកបង្កជាបញ្ហានេះ ដូចជា ថ្លៃចំណាយរស់នៅខ្ពស់ និងកង្វះលំនៅឋានតម្លៃថោកល្មម អសមភាពនៃប្រាក់ចំណូល និងលទ្ធភាពប្រើប្រាស់ប្រភពធនធាននៅមានកម្រិត។ ពលរដ្ឋនៃខោនធី Alameda ស័ក្តិសមតែរស់នៅនៅទីកន្លែងគ្មានការលំបាកផ្នែកសេដ្ឋកិច្ច ដើម្បីរីកចម្រើនថ្កុំថ្កើនទាំងផ្លូវចិត្ត ផ្លូវកាយ និងហិរញ្ញវត្ថុ។

**សេចក្តីសម្រេចអំពីការផ្តល់មូលនិធិ៖**

នឹងមានសេចក្តីសម្រេចអំពីការផ្តល់ជំនួយមូលនិធិចំនួនរហូតដល់ 3។ ជំនួយមូលនិធិមិនត្រូវមានចំនួនលើស $175,000 ឡើយ ក្នុងមួយអង្គការ/ស្ថាប័ន។

ជំនួយមូលនិធិនឹងត្រូវប្រើប្រាស់ដើម្បីបង់សងផ្ទាល់ទៅឲ្យអ្នកចូលរួមក្នុងកម្មវិធីធានាប្រាក់ចំណូល តាមរបៀបមួយ ឬច្រើន ដូចខាងក្រោម៖

- បង្កើនចំនួនអ្នកចូលរួមក្នុងកម្មវិធីធានាប្រាក់ចំណូល
- បន្ថែមថេរវេលាដែលអ្នកចូលរួមទទួលបាននូវប្រាក់ចំណូលដែលបានធានា។
- បង្កើនចំនួនប្រាក់ប្រចាំខែ ដែលអ្នកចូលរួមក្នុងកម្មវិធីទទួលបាន។

**អង្គការ/ស្ថាប័ន ដែលមានលក្ខណសម្បត្តិស្នើសុំមូលនិធិ៖**

- អង្គការ/ស្ថាប័នត្រូវតែកំពុងអនុវត្តកម្មវិធីធានាប្រាក់ចំណូល ឬក៏កំពុងស្ថិតក្នុងដំណើរការចាប់ផ្តើមក្រុមបន្ថែម ដែលឧបត្ថម្ភគាំទ្រដល់ពលរដ្ឋនៃខោនធី Alameda ដែលមានទ្រព្យ ចំណូលតិចតួច និងស្ថិតក្នុងប្រភេទក្រុមមួយ ក្នុងចំណោមប្រភេទក្រុមខាងក្រោម៖
    - គ្រួសារមានកូនតូចយ៉ាងតិចម្នាក់ (អាយុពី សូន្យ ទៅ 8 ឆ្នាំ)
    - យុវជនចេញពីកន្លែងចិញ្ចឹមថែទាំ និង/ឬប្រព័ន្ធយុត្តិធម៌អនីតិជន
    - ចាស់ជរា
    - ស្ត្រីផ្ទៃពោះមានហានិភ័យខ្ពស់នៃការសម្រាលកូនមុនទាន់គ្រប់ខែ
- អង្គការ/ស្ថាប័នត្រូវតែមានទីតាំងស្ថិតនៅក្នុងខោនធី Alameda (ត្រូវតែមានទីតាំងរបវន្តនៅក្នុងខោនធី Alameda)

- អង្គការ/ស្ថាប័នត្រូវតែជាអង្គការ/ស្ថាប័នមិនរកប្រាក់ចំណេញ មានឋានៈតាមមាត្រា 501(c)(3) ឬអ្នកស្នើសុំ ដែលបំពេញមុខងារដូចអង្គការ/ស្ថាប័នមិនរកប្រាក់ចំណេញ អាចស្នើសុំជាមួយអ្នកឧបត្ថម្ភហិរញ្ញវត្ថុ (លក្ខខណ្ឌឯកសារៈ ការដាក់លិខិតបញ្ជាក់ឋានៈលើកលែងពន្ធរបស់រដ្ឋសហព័ន្ធ (Federal Tax-Exempt Status Letter)។ ប្រសិនបើប្រើអ្នកឧបត្ថម្ភហិរញ្ញវត្ថុ ការដាក់លិខិតបញ្ជាក់ឋានៈលើកលែងពន្ធរបស់រដ្ឋសហព័ន្ធ និងច្បាប់ចម្លងនៃកិច្ចព្រមព្រៀងឧបត្ថម្ភហិរញ្ញវត្ថុ)។

**សូមកត់សម្គាល់៖** ប្រសិនបើអង្គការ/ស្ថាប័នរបស់អ្នកត្រូវបានជ្រើសរើស និងមិនធ្លាប់ទទួលបានប្រាក់ពីខោនធី Alameda ពីមុនទេ អ្នកនឹងត្រូវបំពេញការចុះឈ្មោះអ្នកផ្តល់សេវាជាមួយខោនធី មុនពេលគេអាចបើកមូលនិធិឲ្យបាន។ នីតិវិធីនេះ រួមបញ្ចូល ការដាក់ទម្រង់ **W-9** ដែលបានបំពេញរួច (លក្ខខណ្ឌឯកសារៈ ទម្រង់ W-9 ត្រូវតែជាទម្រង់ IRS Version Re. March 2024 ដែលបានចុះហត្ថលេខា និងចុះកាលបរិច្ឆេទក្នុងឆ្នាំ 2025។ *សម្គាល់៖ ការអនុលោមតាមលក្ខខណ្ឌនេះ គឺសំខាន់បំផុត)*។ យើងលើកទឹកចិត្តយ៉ាងខ្លាំងឲ្យអ្នកដាក់ទម្រង់ W-9 ជាមួយពាក្យសុំរបស់អ្នក ដើម្បីជួយសម្រួលដល់នីតិវិធី ប្រសិនបើអ្នកត្រូវបានជ្រើសរើស។

សេចក្តីសម្រេចចុងក្រោយអំពីការផ្តល់ជំនួយមូលនិធិ នឹងត្រូវពឹងផ្អែកលើចំនួនអ្នកស្នើសុំដែលមានលក្ខណសម្បត្តិ លើការវាយតម្លៃពាក្យសុំផ្អែកលើលក្ខណៈវិនិច្ឆ័យ និងលើលទ្ធភាពមានមូលនិធិ។ ដោយដាក់ពាក្យសុំក្នុងកម្មវិធីជំនួយមូលនិធិនេះ អ្នកស្នើសុំមិនត្រូវបានធានាថា នឹងទទួលបានជំនួយមូលនិធិឡើយ។ ខោនធី Alameda តាមរយៈទីភ្នាក់ងារសេវាកម្មសង្គមកិច្ច (Social Services Agency) រក្សាសិទ្ធិធ្វើការកែប្រែផ្នែកណាមួយនៃនីតិវិធីនេះ ឬកម្មវិធីទាំងមូល តាមរបៀបណាក៏បាន ដើម្បីភាពងាយស្រួលរបស់ខោនធី នៅពេលណាក៏បាន។

សូមពិគ្រោះយោបល់ជាមួយអ្នកវិជ្ជាជីវៈវិស័យពន្ធដាររបស់អង្គការ/ស្ថាប័នរបស់អ្នកអំពីលក្ខខណ្ឌតម្រូវនៃការរាយការណ៍អំពីប្រាក់ពន្ធ។

## លក្ខណសម្បត្តិអប្បបរមា

- **អង្គការ/ស្ថាប័ន៖** អង្គការ/ស្ថាប័នស្នើសុំ ត្រូវតែមានការិយាល័យស្ថិតនៅក្នុងខោនធី Alameda។
- **ការផ្តោតលើភូមិសាស្ត្រ៖** កម្មវិធីត្រូវតែបម្រើសេវាកម្មផ្ទាល់ជូនពលរដ្ឋកំពុងស្នាក់នៅក្នុងខោនធី Alameda។
- **ការបង្កើតកម្មវិធី និងបទពិសោធន៍៖** អង្គការ/ស្ថាប័នស្នើសុំ ត្រូវតែបង្ហាញថា កម្មវិធីធានាប្រាក់ចំណូលរបស់ខ្លួន ត្រូវបានបង្កើតរួចហើយ ដោយបានបើកប្រាក់ដោយជោគជ័យទៅឲ្យអ្នកចូលរួម និងរួមបញ្ចូលបទពិសោធន៍ក្នុងសកម្មភាពផ្សព្វផ្សាយដល់អ្នកចូលរួម ការចុះឈ្មោះ និងការចែកចាយប្រាក់។

- **ម៉ូដែលកម្មវិធី និងការវាយតម្លៃ៖** អង្គការ/ស្ថាប័នស្នើសុំ ត្រូវតែដាក់បញ្ជូននូវម៉ូដែលកម្មវិធីដែលច្បាស់លាស់ ដែលគូសបញ្ជាក់ពីលក្ខណៈវិនិច្ឆ័យនៃលក្ខណសម្បត្តិចូលរួម វិធីចែកចាយប្រាក់ និងសេវាកម្មគាំទ្រ ដែលបានផ្តល់ជូន។ លើសពីនេះ គួរបញ្ចូលនូវផែនការបឋមសម្រាប់វាយតម្លៃកម្មវិធី រាប់បញ្ចូលទាំង សូចនាករសំខាន់ៗ ដែលស្នើឡើង សម្រាប់វាយតម្លៃលើផលប៉ះពាល់។

- **ការប្តេជ្ញាចំពោះលទ្ធផលប្រកបដោយសមធម៌៖** រចនាប្លង់នៃកម្មវិធីគួរបង្ហាញពីការប្តេជ្ញាផ្តល់សេវាកម្មដល់សហគមន៍ចម្រុះក្នុងខោនធី Alameda។ អ្នកស្នើសុំគួររៀបរាប់ពីយុទ្ធសាស្ត្ររបស់ខ្លួនសម្រាប់ការផ្សព្វផ្សាយ និងការចុះឈ្មោះប្រកបដោយសមធម៌ ដើម្បីធានាដល់ការប្រើប្រាស់កម្មវិធីយ៉ាងទូលំទូលាយ។

**លក្ខណៈវិនិច្ឆ័យលើសំណើ**

រាល់ពាក្យសុំទាំងអស់ នឹងត្រូវបានពិនិត្យលើភាពពេញលេញ និងដើម្បីធានាថា ពាក្យសុំបំពេញនូវលក្ខខណ្ឌតម្រូវអប្បបរមា មុនពេលគណៈកម្មាធិការត្រួតពិនិត្យមួយ ធ្វើការវាយតម្លៃពាក្យសុំ ផ្អែកលើលក្ខណៈវិនិច្ឆ័យ ដើម្បីជ្រើសរើស និងផ្តល់ជាអនុសាសន៍លើពាក្យសុំសម្រាប់ការផ្តល់មូលនិធិ។ សំណើនឹងត្រូវវាយតម្លៃ ផ្អែកលើចំណុចដូចខាងក្រោម៖

- **ការផ្តោតលើភូមិសាស្ត្រ និងវត្ថុបំណងនៃកម្មវិធី៖** កម្មវិធីត្រូវតែផ្តល់ជាផែនការច្បាស់លាស់សម្រាប់ផ្តល់ឲ្យអ្នកចូលរួមទាំងអស់ដែលបច្ចុប្បន្នជាពលរដ្ឋរបស់ខោនធី Alameda។ 15 ពិន្ទុ
- **ការបង្កើតកម្មវិធី និងបទពិសោធន៍៖** កម្មវិធីត្រូវបង្ហាញថា កម្មវិធីធានាប្រាក់ចំណូលរបស់ខ្លួន គឺបានបង្កើតរួចហើយ និងរៀបរាប់ឲ្យបានច្បាស់អំពីដំណើរការផ្សព្វផ្សាយដល់អ្នកចូលរួម ការចុះឈ្មោះ និងការចែកចាយប្រាក់។ 15 ពិន្ទុ
- **ម៉ូដែលកម្មវិធី និងវិធីសាស្ត្រ៖** ម៉ូដែលកម្មវិធីត្រូវតែកំណត់ឲ្យបានច្បាស់លាស់អំពីលក្ខណសម្បត្តិរបស់អ្នកចូលរួម រចនាសម្ព័ន្ធបង់ប្រាក់ និងសេវាកម្មគាំទ្រ ដោយបង្ហាញពីទំនាក់ទំនងច្បាស់លាស់ជាមួយនឹងគោលការណ៍ និងគុណតម្លៃដឹកនាំរបស់កម្មវិធី។ 15 ពិន្ទុ
- **ការចូលរួម និងភាពជាដៃគូរបស់សហគមន៍៖** អ្នកស្នើសុំត្រូវតែបង្ហាញពីទំនាក់ទំនងសង្គម ភាពជាដៃគូ និងយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់ការចូលរួមពីសំណាក់ពលរដ្ឋនៃខោនធី Alameda ដើម្បីគាំទ្រដល់កម្មវិធីរបស់ខ្លួន។ 15 ពិន្ទុ
- **ផលប៉ះពាល់នៃកម្មវិធី និងការវាយតម្លៃ៖** កម្មវិធីត្រូវតែកំណត់សូចនាករសំខាន់ៗ សម្រាប់វាយតម្លៃភាពជោគជ័យលើសពីសូចនាករ និងបង្ហាញពីសមត្ថភាពប្រមូល និងប្រើប្រាស់ទិន្នន័យជាព័ត៌មានសម្រាប់ការងាររបស់ខ្លួន។ 15 ពិន្ទុ
- **សមត្ថភាពស្ថាប័ន និងនិរន្តភាព៖** អង្គការ/ស្ថាប័នត្រូវតែបង្ហាញពីហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពក្នុងការអនុវត្ត និងតាមដាននូវកម្មវិធីធានាប្រាក់ចំណូល និងគ្រប់គ្រងជំនួយមូលនិធិប្រកបដោយប្រសិទ្ធភាព។ 10 ពិន្ទុ

- **ផែនការហិរញ្ញវត្ថុ និងថវិកា៖** សំណើថវិកាត្រូវតែមានភាពជាក់ស្តែង មូលហេតុច្បាស់លាស់ និងបង្ហាញច្បាស់ពីប្រសិទ្ធភាពចំណាយក្នុងការសម្រេចនូវគោលដៅរបស់កម្មវិធី។ 15 ពិន្ទុ

**ដំណើរការនៃការវាយតម្លៃ**

ពាក្យសុំត្រូវបានវាយតម្លៃដោយគណៈកម្មាធិការត្រួតពិនិត្យជំនួយមូលនិធិ (Grant Review Committee) របស់ទីភ្នាក់ងារសេវាកម្មសង្គមកិច្ចនៃខោនធី Alameda ដែលរួមមានបុគ្គលិកទីភ្នាក់ងារ អ្នកតំណាងសហគមន៍ និងអ្នកត្រួតពិនិត្យផ្សេងទៀតដែលមានលក្ខណសម្បត្តិ ជាមួយនឹងបទពិសោធន៍ពាក់ព័ន្ធ។

សេចក្តីសម្រេចអំពីជំនួយមូលនិធិត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការត្រួតពិនិត្យជំនួយមូលនិធិ និងផ្តល់ជាអនុសាសន៍ដល់ប្រធានទីភ្នាក់ងារសេវាកម្មសង្គមកិច្ច ដើម្បីអនុម័តឯកភាពចុងក្រោយ។

**សូមកត់សម្គាល់៖** រាល់សេចក្តីសម្រេចអំពីការផ្តល់មូលនិធិទាំងអស់ គឺជាសេចក្តីសម្រេចស្ថាពរ។ ពុំមាននីតិវិធីប្តឹងតវ៉ាលើសេចក្តីសម្រេចអំពីពាក្យសុំឡើយ។ យើងលើកទឹកចិត្តឲ្យអ្នកស្នើសុំត្រូវធានា សំណើរបស់ខ្លួន មានលក្ខណៈពេញលេញ សរសេរច្បាស់លាស់ និងដាក់មកឲ្យបានទាន់ពេលវេលា។ **ពាក្យសុំយឺតយ៉ាវនឹងមិនត្រូវទទួលយកឡើយ។** រាល់ឯកសារពាក្យសុំទាំងអស់ត្រូវតែដាក់មកតាមអ៊ីម៉ែលតែមួយគត់។ ឯកសារជាសន្លឹកក្រដាសនឹងមិនត្រូវទទួលយកឡើយ។

## លក្ខខណ្ឌរាយការណ៍ពីជំនួយមូលនិធិ

ប្រសិនបើត្រូវបានជ្រើសរើសសម្រាប់ឱកាសនេះ អ្នកទទួលមូលនិធិនឹងត្រូវបានតម្រូវឲ្យដាក់របាយការណ៍ចុងក្រោយមក**ទីភ្នាក់ងារសេវាកម្មសង្គមកិច្ចខោនធី Alameda** ដែលរាយការណ៍លម្អិតអំពីលទ្ធផល ផលប៉ះពាល់ និងបទពិសោធន៍ ដែលទទួលបានពីគម្រោងដែលទទួលបានមូលនិធិ។ គំរូរបាយការណ៍នឹងត្រូវផ្តល់ជូន ដើម្បីធានានូវភាពស៊ីសង្វាក់គ្នា និងដើម្បីដាក់បញ្ចូលនូវព័ត៌មានសំខាន់ចាំបាច់។ របាយការណ៍ចុងក្រោយត្រូវតែដាក់មកតាមប្រព័ន្ធអេឡិចត្រូនិក នៅត្រឹម**ថ្ងៃទី 30 ខែមីនា ឆ្នាំ 2026។**

របាយការណ៍ចុងក្រោយនឹងដាក់បញ្ចូលចំណុចដូចខាងក្រោម៖

- គោលដៅនៃកម្មវិធី និងវឌ្ឍនភាពក្នុងអំឡុងរយៈពេលនៃជំនួយមូលនិធិ។
- ប្រជាជនដែលបានបម្រើសេវាកម្មជូន រាប់បញ្ចូល ព័ត៌មានលម្អិតអំពីប្រជាសាស្ត្ររបស់អ្នកចូលរួម។
- បញ្ហាប្រឈម ឬឧបសគ្គ ដែលបានជួបប្រទះ និងរបៀបដោះស្រាយបញ្ហាប្រឈម ឬឧបសគ្គនោះ។
- គូសបញ្ជាក់ពីរបៀបបែងចែកជំនួយមូលនិធិទៅឲ្យអ្នកចូលរួម
- អត្ថបទរឿងរបស់អ្នកចូលរួម 1-2 នាក់ ដែលគូសបញ្ជាក់ពីផលប៉ះពាល់ (ដោយមានការយល់ព្រមសមរម្យ)

| **បន្ទាត់ពេលវេលា** | |
|---|---|
| **ថ្ងៃកំណត់ត្រូវដាក់ពាក្យសុំ** | **ថ្ងៃទី 10 ខែ តុលា ឆ្នាំ 2025** |
| **អ្នកទទួលមូលនិធិត្រូវបានជ្រើសរើស** | **ចុងខែតុលា ឆ្នាំ 2025** |
| **ការបញ្ចេញមូលនិធិ** | **ខែវិច្ឆិកា/ខែធ្នូ ឆ្នាំ 2025** |
| **របាយការណ៍ចុងក្រោយ** | **ថ្ងៃទី 30 ខែ មីនា ឆ្នាំ 2026** |

**សេចក្តីណែនាំអំពីពាក្យសុំ៖**

- ពាក្យសុំអាចរកបាននៅទំព័រទី 5 ដែលនឹងក្លាយជាគម្របទំព័ររបស់អ្នក។
- សំណួរផ្សេងៗអាចរកបាននៅទំព័រទី 6។
- ចម្លើយគួរវាយបញ្ចូល ដោយប្រើពុម្ពអក្សរ Arial ទំហំ 11 ក្នុងកម្មវិធី word។
- ពាក្យសុំគួរមានចំនួនទំព័រមិនលើសពី 5 ទំព័រឡើយ។
- រាល់ឯកសារពាក្យសុំទាំងអស់ត្រូវតែដាក់ តាមអ៊ីម៉ែលតែមួយគត់ ដែលផ្ញើមក SSAInnovations@acgov.org; ឯកសារជាសន្លឹកក្រដាសនឹងមិនទទួលយកឡើយ។

  *សូមផ្ញើសំណួរអំពីពាក្យសុំ ឬដំណើរការនៃពាក្យសុំទៅ៖* SSAInnovations@acgov.org.

| ពាក្យសុំ<br>ព័ត៌មានអំពីកម្មវិធី | |
|---|---|
| **ឈ្មោះអង្គការ/ស្ថាប័នស្នើសុំ** | |
| **ឈ្មោះកម្មវិធីធានាប្រាក់ចំណូល (G.I. Program)**<br><br>**ប្រសិនបើខុសពីឈ្មោះអង្គការ/ស្ថាប័ន** | |
| **អាសយដ្ឋាន** | |
| **ទីតាំងកម្មវិធី**<br><br>**ទីក្រុង/សង្កាត់/កូដ/Zip)*<br><br>*តំបន់ភូមិសាស្ត្រដែលបម្រើសេវាកម្ម* | |
| **ថេរវេលានៃកម្មវិធីធានាប្រាក់ចំណូល** | |
| **បុគ្គលចម្បងដែលត្រូវទាក់ទង**<br><br>**សូមសរសេរឈ្មោះ តំណែង/ឋានៈ អ៊ីម៉ែល,*<br><br>*លេខទូរស័ព្ទ** | |
| **បុគ្គលបន្ទាប់បន្សំដែលត្រូវទាក់ទង**<br>** សូមសរសេរឈ្មោះបុគ្គលបន្ទាប់បន្សំដែលត្រូវទាក់ទង ប្រសិនបើមាន** | |

## សំណួរ

1. សូមរៀបរាប់អំពីគោលបំណងចម្បងនៃកម្មវិធីរបស់អ្នកសម្រាប់ជំនួយមូលនិធិនេះ។ (អ្នកអាចជ្រើសយកជម្រើសផ្សេងៗ ដូចខាងក្រោម។)
    a. យើងគ្រោងៈ
        i. បង្កើនចំនួនអ្នកចូលរួមក្នុងកម្មវិធីធានាប្រាក់ចំណូលបច្ចុប្បន្នរបស់យើង។
        ii. បន្ថែមថេរវេលាដែលអ្នកចូលរួមទទួលបានប្រាក់ចំណូលដែលបានធានានៅក្នុងកម្មវិធីរបស់យើង។
        iii. បង្កើនចំនួនប្រាក់ចំណូលដែលបានធានា ដែលអ្នកចូលរួមស្រាប់ទទួលបាន។
2. ការបង្កើតកម្មវិធី និងបទពិសោធន៍
    a. រៀបរាប់ពីស្ថានភាពនៃកម្មវិធីធានាប្រាក់ចំណូលបច្ចុប្បន្នរបស់អ្នក។ តើកម្មវិធីបង្កើតឡើងនៅពេលណា? គិតត្រឹមថ្ងៃនេះ តើកម្មវិធីបានដំណើរការរយៈពេលប៉ុន្មានហើយ?
    b. តើមានគ្រួសារ ឬបុគ្គលចំនួនប៉ុន្មាន ដែលឧបត្ថម្ភដោយកម្មវិធីរបស់អ្នកនាបច្ចុប្បន្ន? ប្រសិនបើមានផែនការសកម្មភាព ដើម្បីពង្រីក និងបម្រើដល់គ្រួសារច្រើនថែមទៀត សូមគូសបញ្ជាក់ខ្លីៗអំពីផែនការនោះ។
    c. រៀបរាប់ពីដំណើរការផ្សព្វផ្សាយដល់អ្នកចូលរួម ការចុះឈ្មោះ និងការចែកចាយប្រាក់ឧបត្ថម្ភ។ សូមផ្តល់ភស្តុតាងបញ្ជាក់ពីការអនុវត្តដំណើរការទាំងនេះទទួលបានជោគជ័យ។
3. ម៉ូដែលកម្មវិធី និងវិធីសាស្ត្រ
    a. រៀបរាប់ពីម៉ូដែលកម្មវិធីធានាប្រាក់ចំណូលបច្ចុប្បន្នរបស់អ្នក រាប់បញ្ចូលទាំង លក្ខណសម្បត្តិរបស់អ្នកចូលរួម រចនាសម្ព័ន្ធបើកប្រាក់ និងសេវាកម្មគាំទ្រ។
    b. តើមានគោលការណ៍ ឬគុណតម្លៃអ្វីខ្លះដែលកំណត់ពីកម្មវិធីរបស់អ្នក ហើយតើគោលការណ៍ ឬគុណតម្លៃទាំងនេះបានបង្ហាញច្បាស់ក្នុងការងាររបស់អ្នកជាមួយនឹងពលរដ្ឋនៃខោនធី Alameda ដោយរបៀបណា?
4. ការចូលរួម និងភាពជាដៃគូរបស់សហគមន៍
    a. រៀបរាប់ពីទំនាក់ទំនងសំខាន់របស់អង្គការ/ស្ថាប័នរបស់អ្នកក្នុងខោនធី Alameda និងវិធីដែលអ្នកធ្វើឲ្យសហគមន៍ចូលរួមគាំទ្រដល់កម្មវិធីរបស់អ្នក និងអ្នកចូលរួម។
    b. តើអ្នកមានភាពជាដៃគូស្រាប់ជាមួយនឹងអង្គការ/ស្ថាប័នផ្សេងទៀត ដែលបម្រើដល់ពលរដ្ឋនៃខោនធី Alameda ដែរឬទេ? ប្រសិនបើមាន សូមរៀបរាប់ខ្លីៗអំពីភាពជាដៃគូសំខាន់ៗ និងផលប៉ះពាល់លើកម្មវិធីរបស់អ្នក។
5. ផលប៉ះពាល់នៃកម្មវិធី និងការវាយតម្លៃ
    a. រៀបរាប់ខ្លីៗអំពីសូចនាករសំខាន់ៗ ដែលប្រើដើម្បីវាយតម្លៃលើភាពជោគជ័យ និងផលប៉ះពាល់នៃកម្មវិធីធានាប្រាក់ចំណូល? ឧទាហរណ៍នៃសូចនាករៈ លទ្ធផលជាស្ថេរភាពលំនៅឋាន ការផ្លាស់ប្តូរឋានៈការងារ សុខភាពផ្លូវចិត្ត/សុខមាលភាព វិធានការសន្តិសុខហិរញ្ញវត្ថុ និងលទ្ធផលអប់រំ/សុខមាលភាពកុមារ។
    b. រៀបរាប់ខ្លីៗអំពីសមត្ថភាពប្រមូលទិន្នន័យ និងរបៀបដែលអ្នកប្រើទិន្នន័យជាព័ត៌មានសម្រាប់កម្មវិធីរបស់អ្នក។
    c. រៀបរាប់លម្អិតខ្លីៗអំពីលទ្ធផលទាំងមូលនៃកម្មវិធី គិតត្រឹមកាលបរិច្ឆេទនេះ។
6. សមត្ថភាពស្ថាប័ន និងនិរន្តរភាព
    a. រៀបរាប់ខ្លីៗអំពីបទពិសោធន៍របស់អង្គការ/ស្ថាប័នរបស់អ្នកក្នុងការអនុវត្តកម្មវិធីជំនួយហិរញ្ញវត្ថុផ្ទាល់ និងក្នុងការបម្រើសេវាកម្មដល់ពលរដ្ឋនៃខោនធី Alameda។
    b. រៀបរាប់លម្អិតខ្លីៗអំពីតួនាទី និងការទទួលខុសត្រូវរបស់បុគ្គលិកសំខាន់ៗ ដែលអនុវត្តកម្មវិធី ធានាប្រាក់ចំណូលរបស់អ្នក។